# Noble Park English Language School

21-35 Thomas Street, Noble Park, 3174.
P.O. Box 656, Noble Park, 3174

Telephone: 9546 9578
Fax: 9558 5683
email: noble.park.els@edumail.vic.gov.au
ABN: 67 406 080 234


នៅឆ្នាំ 2016 ការអប់រំទំនាក់ទំនងប្រកបដោយការគោរព (RR) បានក្លាយជាសមាសភាគដ៏សំខាន់មួយនៃកម្មវិធីសិក្សារដ្ឋវិចថូរៀ។ កម្មវិធីនេះកកើតឡើងបន្ទាប់ពីរាជគណៈកម្មការស៊ើបអង្កេតសាធារណៈជាផ្លូវការ (Royal Commission) លើមរណភាពគួរឱ្យខ្លោចផ្សារបស់ Luke Batty ក្នុងឆ្នាំ 2014។ វាជាអនុសាសន៍របស់រាជគណៈកម្មការស៊ើបអង្កេតសាធារណៈជាផ្លូវកា ដែលថាសាលាទាំងអស់បង្រៀនការអប់រំទំនាក់ទំនងប្រកបដោយការគោរព (RR) តាមរយៈវិធីសាស្រ្តសាលាទាំងមូលធ្វើការរួមគ្នា ដើម្បីជួយសិស្សឱ្យទទួលស្គាល់ និងគ្រប់គ្រងអារម្មណ៍ អភិវឌ្ឍការយល់ចិត្តអ្នកដទៃ ហើយបង្កើត និងកសាងក្របខ័ណ្ឌមួយសម្រាប់ទំនាក់ទំនងវិជ្ជមាន។

សម្ភារៈបង្រៀន និងការរៀនសូត្រអំពីភាពធន់ទ្រាំ សិទ្ធិ និងទំនាក់ទំនងប្រកបដោយការគោរព ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់សាលារៀននានាក្នុងការផ្តល់កម្មវិធីសិក្សា និងត្រូវបានតម្រូវឱ្យបង្រៀននៅក្នុងសាលារដ្ឋវិចថូរៀទាំងអស់។

នៅសាលាភាសាអង់គ្លេសណូប៊ិល ផាក (Noble Park English Language) យើងទាំងអស់គ្នាចង់ឱ្យកូនៗរបស់យើងទទួលបានការអប់រំដែលផ្តល់ឱ្យពួកគេនូវការចាប់ផ្តើមដ៏ល្អបំផុតសម្រាប់ជីវិតដ៏រីករាយ មានសុខភាពល្អ និងចម្រុងចម្រើន។ វិធីសាស្រ្តនេះនាំទៅរកការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងលទ្ធផលសិក្សារបស់សិស្ស សុខុមាលភាពរបស់ពួកគេ អាកប្បកិរិយាក្នុងថ្នាក់រៀន និងទំនាក់ទំនងរវាងគ្រូ ហើយនិងសិស្ស។ យើងដឹងថាការផ្លាស់ប្តូរក្នុងឥរិយាបទ និងអាកប្បកិរិយាអាចសម្រេចបាន នៅពេលដែលឥរិយាបទវិជ្ជមាន អាកប្បកិរិយា និងសមភាពយេនឌ័របានបន្តរស់នៅទូទាំងសហគមន៍សាលារៀន។ រួមគ្នា យើងអាចដឹកនាំផ្លូវក្នុងការបង្កើតការផ្លាស់ប្តូរពិតប្រាកដ និងយូរអង្វែង ដើម្បីឱ្យកុមារគ្រប់រូបមានឱកាសសម្រេចបាននូវសក្តានុពលពេញលេញរបស់ពួកគេ។

**កម្មវិធីថ្នាក់រៀននឹងផ្តោតលើផ្នែកសំខាន់ៗចំនួន 8៖**

- **អក្ខរកម្មផ្លូវអារម្មណ៍៖** នេះជួយសិស្សអភិវឌ្ឍសមត្ថភាពក្នុងការយល់ដឹង យល់ និងប្រើវាក្យសព្ទអំពីស្ថានភាពអារម្មណ៍របស់ខ្លួននិងអ្នកដទៃប្រកបដោយប្រសិទ្ធភាព។
- **ភាពរឹងមាំផ្ទាល់ខ្លួន៖** សិស្សបង្កើតវាក្យសព្ទដើម្បីជួយពួកគេឱ្យស្គាល់ និងយល់ដឹងពីភាពរឹងមាំ និងគុណសម្បត្តិវិជ្ជមានផ្សេងៗនៅក្នុងខ្លួន និងអ្នកដទៃ។ ពួកគេកំណត់អត្តសញ្ញាណភាពរឹងមាំដែលពួកគេកោតសរសើរចំពោះអ្នកដ៏ទៃ និងអស់អ្នកដែលពួកគេត្រូវការដើម្បីទាក់ទិនជាមួយបញ្ហាប្រឈម និងឱកាសនានាដែលជីវិតឆ្លងកាត់។
- **ការទប់ទល់ដោយវិជ្ជមាន៖** សិស្សបង្កើតភាសាជុំវិញការទប់ទល់ ឆ្លុះបញ្ចាំងយ៉ាងជិតដល់លើយុទ្ធសាស្រ្តទប់ទល់របស់ពួកគេ និងពង្រីកជំនាញនានារបស់ពួកគេអំពីយុទ្ធសាស្រ្តទប់ទល់ដោយវិជ្ជមាន។
- **ការដោះស្រាយបញ្ហា៖** សិស្សរៀនបច្ចេកទេសដោះស្រាយបញ្ហាច្រើនប្រភេទ ដែលអាចអនុវត្តនៅពេលប្រឈមមុខនឹងបញ្ហាផ្ទាល់ខ្លួន សង្គម និងសីលធម៍។ ពួកគេចូលរួមក្នុងកិច្ចការរៀនសូត្រដែលបានអនុវត្ត ដែលពួកគេទាក់ទិនជំនាញដោះស្រាយបញ្ហារបស់ពួកគេឱ្យមានភាពប្រាកដនិយម។
- **ការគ្រប់គ្រងស្រ្តេស៖** នេះបង្រៀនសិស្សឱ្យរៀនជំនាញដោះស្រាយបញ្ហាជាច្រើន តាមរយៈកិច្ចការរៀនសូត្រដែលបានអនុវត្ត ដើម្បីឱ្យពួកគេអាចទប់ទល់នឹងបញ្ហាប្រឈមនៅពេលកើតមាន។
- **ការស្វែងរកជំនួយ៖** ការស្វែងរកជំនួយគឺជាយុទ្ធសាស្រ្តទប់ទល់មួយ ដែលពាក់ព័ន្ធនឹងការស្វែងរកការគាំទ្រផ្នែកបច្ចេកទេស ជាឧបករណ៍ សង្គម ឬអារម្មណ៍ពីមនុស្សផ្សេងទៀត។
- **យេនឌ័រ និងអត្តសញ្ញាណ៖** ទាំងនេះគឺជាសកម្មភាពរៀនសូត្រតាមអាយុដែលជួយសិស្សឱ្យយល់ដឹង និងរិះគន់ឥទ្ធិពលនៃបទដ្ឋានយេនឌ័រលើឥរិយាបទ និងអាកប្បកិរិយា (សូមមើលឃ្លីបភ្ជាប់ខាងក្រោមសម្រាប់ឧទាហរណ៍នៃការរម្លឹកលើការពិភាក្សា)។
- **ទំនាក់ទំនងយេនឌ័រវិជ្ជមាន៖** នេះបង្រៀនសិស្សឱ្យបង្កើតទំនាក់ទំនងវិជ្ជមានរវាង និងនៅក្នុងយេនឌ័រ ហើយនិងសារៈសំខាន់នៃការទទួលយកភាពខុសគ្នា និងភាពចម្រុះ។

ទំនាក់ទំនងប្រកបដោយការគោរព ត្រូវប្រើវិធីសាស្រ្តសាលាទាំងមូលធ្វើការរួមគ្នា ដោយទទួលស្គាល់ថាសាលារៀនគឺជាកន្លែងរៀនសូត្រ កន្លែងធ្វើការ និងជាផ្នែកសំខាន់មួយនៃសហគមន៍មូលដ្ឋាន។ វាបង្កប់នូវវប្បធម៌នៃការគោរព និងសមភាពនៅទូទាំងសហគមន៍សាលារបស់យើងទាំងមូល ចាប់ពីថ្នាក់រៀនរបស់យើង រហូតដល់បន្ទប់បុគ្គលិក ទីលានកីឡា ព្រឹត្តិការណ៍សាលា និងព្រឹត្តិការណ៍សង្គម។

សិស្សរបស់យើងនឹងចូលរួមក្នុងមេរៀន RR រៀងរាល់សប្តាហ៍ ឬរៀងរាល់ពីរសប្តាហ៍នៅក្នុងថ្នាក់រៀនរបស់ពួកគេ សកម្មភាពក្រុម ឬនៅទូទាំងសន្និបាតសាលា។ ដោយសារលក្ខណៈបណ្តោះអាសន្ននៃក្រុមសាលារបស់យើង យើងធ្វើតាមផែនការអនុវត្តរាល់ឆមាសនីមួយៗ ដើម្បីគ្របដណ្តប់លើផ្នែកសំខាន់ៗទាំងអស់។

ឧទាហរណ៍ ថ្នាក់ទី 5 និងទី 6 នៃគម្រោងផ្នែកសំខាន់ៗដូចមានផ្តល់ខាងក្រោម៖

| **យេនឌ័រ និងអត្តសញ្ញាណ** | **ទំនាក់ទំនងយេនឌ័រវិជ្ជមាន** |
|---|---|
| មាតិកាត្រីមាសទី 2 និងទី 4 | មាតិកាត្រីមាសទី 2 និងទី 4 |

| | |
|---|---|
| • កើត ឬបង្កើត? ការគិតអំពីយេនឌ័រ (ជាតួយ៉ាង)<br>• ពីពាក្យពេជន៍ ទៅសកម្មភាព (ការគោរពភាពខុសគ្នា)<br>• បទដ្ឋានយេនឌ័រក្នុងវ័យជំទង់ដំបូង<br>• ការពិតអំពីយេនឌ័រ និងឱកាស<br>• ការបង្កើនការយល់ដឹងអំពីសិទ្ធិមនុស្ស<br>• ម៉ាស៊ីនយេនឌ័រអន្តរជំនាន់ | • តើអំពើហិង្សាគឺជាអ្វី?<br>• តើអ្វីទៅជាអំពើហិង្សាផ្អែកលើយេនឌ័រ?<br>• ការយល់ដឹងអំពីទំនាក់ទំនងអំណាច<br>• ការគោរពយ៉ាងសកម្មក្នុងទំនាក់ទំនងមិត្តភ័ក្តិ<br>• តើអ្វីទៅការបៀតបៀនផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ?<br>• ការគាំទ្រពីមិត្តភ័ក្តិ៖ ការកំណត់ព្រំដែន ស្តង់ដារទំនាក់ទំនង (ការយល់ព្រមក៏នឹងត្រូវបានរួមបញ្ចូលនៅទីនេះផងដែរ។)<br>• ការស្វែងរកជំនួយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាផ្អែកលើយេនឌ័រ |

ពេញមួយឆ្នាំ យើងនឹងប្រារព្ធពីកិច្ចការដែលបានធ្វើក្នុងអំឡុងពេលវគ្គ RR ដោយរួមបញ្ចូលរូបថត និងការពិពណ៌នាអំពីមេរៀននានា ក្នុងការអបអរសាទរអំពីការខិតខំប្រឹងប្រែងរបស់សិស្សនៅក្នុងថ្នាក់។

កម្មវិធីទំនាក់ទំនងប្រកបដោយការគោរព នឹងត្រូវបានផ្តល់ជូនតាមរបៀបមួយដែលមានលក្ខណៈរសើប និងអនុគ្រោះចំពោះគោលនយោបាយសុខុមាលភាពសិស្សរបស់យើង។

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែមអំពីកម្មវិធីសិក្សាទំនាក់ទំនងប្រកបដោយការគោរព សូមទាក់ទង______________________ នៅសាលាភាសាអង់គ្លេសណូប៊ិល ផាក (Noble Park English Language) តាមទូរសព្ទលេខ_____________________។